# កិច្ចព្រមព្រៀងគម្រោង

*******

## រវាង

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ជាមួយនឹង

## អង្គការ LITTLE HEARTS ORGANIZATION

**សង្ខេបគម្រោងកម្មវិធី**

- ឈ្មោះគម្រោង៖ មណ្ឌលកុមារកំព្រាបេះដូងតូច និងជួយកុមារក្នុងសហគមន៍
- ឈ្មោះស្ថាប័នអនុវត្តគម្រោង៖ អង្គការបេះដូងតូច Little Hearts Organization
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ ផ្លូវលេខ៣៨០អា ភូមិទួលមាស សង្កាត់អរិយក្សត្រ ក្រុងអរិយក្សត្រ ខេត្តកណ្តាល ទូរស័ព្ទ៖012 204 308 / 085 769 046 ប្រអប់សំបុត្រ៖ អ៊ីម៉ែល៖ centermanager@lho.ngo
- អង្គការមិនមែនរដ្ឋាភិបាលបរទេស៖ នៅប្រទេសបែលហ្ស៊ិក ផ្ទះលេខ VZW Little Hearts -Reg No: 811643936 Molenlei 18-2530 Boechout- Belgium ទូរស័ព្ទ៖ (32)-497 940-679 អ៊ីម៉ែល៖ info@littlehearts.be, www.lho.ngo
- ថិរៈវេលារបស់គម្រោង៖ ៣ឆ្នាំ
  -ចាប់ផ្តើម៖ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥
  -បញ្ចប់៖ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៨
- ថវិកាគម្រោងសរុប៖ **៥៣៩ 000 ដុល្លារអាមេរិក**
- អ្នកផ្តល់ថវិកាគាំទ្រគម្រោង៖

| ឈ្មោះស្ថាប័នផ្តល់ថវិកា | ប្រភពថវិកា | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|---|
| La On | បែលហ្ស៊ិក | ៣0 000 |
| Recodin | | ៣0 000 |
| Hout Handel Martens | | ៤0 000 |
| Campus Contern | | ៤៥ 000 |
| សប្បុរសជនក្រៅប្រទេស | | ៣៩៤ 000 |
| **សរុប** | | ៥៣៩ 000 |

- គណនីប្រើប្រាស់ថវិកាខាងលើនៅក្នុងប្រទេសកម្ពុជា៖ ធនាគារ អេប៊ីអេ (ABA Bank) ឈ្មោះគណនី: Little Hearts Organization លេខគណនី: 000 508 182 ។
- ប្រភពថវិកាដែលបានផ្តល់ខាងលើទាំងនេះត្រូវតែជាថវិកា ជួយដល់ក្រុមគោលដៅមនុស្សធម៌សុទ្ធសាធ គ្មានការពាក់ព័ន្ធទៅនឹងកិច្ចការយោធា នយោបាយ ឬសាសនាឡើយ។

| ចំនួនបុគ្គលិក | ស្រី | ប្រុស | សរុប |
|---|---|---|---|
| បុគ្គលិកខ្មែរ | ២ | ៤ | ៦ |
| បុគ្គលិកបរទេស | ៣ | ១ | ៤ |
| ចំនួនបុគ្គលិកសរុប | ៥ | ៥ | ១០ |

### គោលដៅកិច្ចសហប្រតិបត្តិការ

- ផ្តល់ការថែទាំរយៈពេលវែងក្នុងបរិយាកាសជាលក្ខណៈគ្រួសារ ដល់កុមារកំព្រា និងកុមារងាយរងគ្រោះ នៅក្នុងមណ្ឌលថែទាំកុមារ ដើម្បីឱ្យស្ថានភាពរស់នៅប្រចាំថ្ងៃរបស់កុមារកាន់តែប្រសើរឡើង
- ផ្តល់ការឧបត្ថម្ភដល់កុមារក្នុងសហគមន៍ និងគ្រួសារ នូវគ្រឿងឧបភោគបរិភោគ សំលៀកបំពាក់ សម្ភារសិក្សា សេវាថែទាំសុខភាព និងការសិក្សាភាសាអង់គ្លេស ការលេងកំសាន្ត និងកីឡា ដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អដែលមានលទ្ធភាព និងសមត្ថភាពរស់នៅខ្លួនឯងក្នុងសហគមន៍។

## ពណ៌នាគម្រោងកម្មវិធី

គម្រោងនេះបង្កើតឡើងបន្ទាប់ពីពិនិត្យឃើញថា មានកុមាររងគ្រោះ និងងាយរងគ្រោះ មួយចំនួនតូច កំពុងរស់នៅក្នុងស្ថានភាពលំបាកនៅឡើយ ដូច្នេះហើយទើបអង្គការ Little Hearts Organization បង្កើតគម្រោងនេះឡើងដើម្បីបន្តផ្តល់ការស្នាក់នៅ ម្ហូបអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព ដល់កុមារ ដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អ មានលទ្ធភាពរស់នៅដោយខ្លួនឯង និងមានសមត្ថភាពក្លាយខ្លួនទៅជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ។

គម្រោងនេះអនុលោមតាមគោលនយោបាយរាជរដ្ឋាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធានាបាននូវប្រយោជន៍ សុខុមាលភាព សុវត្ថិភាព និងការអភិវឌ្ឍន៍ល្អ។

ទីកន្លែងអនុវត្តគម្រោង៖ (រៀបតាមលំដាប់ចំនួនក្រុមគោលដៅទទួលផលពីច្រើនទៅតិច)

១. ខេត្តកណ្តាល៖ ផ្លូវ៣៨០អា ភូមិទួលមាស សង្កាត់អរិយក្សត្រ ក្រុងអរិយក្សត្រ

២. ខេត្តកណ្តាល៖ ភូមិត្រែង សង្កាត់សិត្បូ ក្រុងតាខ្មៅ

ទីកន្លែងដែលអនុវត្តជាក់លាក់ខាងលើអាចនឹងត្រូវបានពង្រីកទៅទីតាំងដទៃទៀត បានតាមសំណើសុំរបស់មន្ទីរ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមាន៖

ក.ធ្វើអោយប្រសើរឡើងនូវស្ថានភាពរស់នៅរបស់កុមារក្នុងមណ្ឌលកុមារបេះដូងតូច កុមារទទួលបាន៖

- ការស្នាក់នៅ អាហារ សម្លៀកបំពាក់ សម្ភារសិក្សា សម្ភារប្រើប្រាស់ និងការថែទាំសុខភាព
- ការអប់រំប្រកបដោយគុណភាព ពីកម្រិតមត្តេយ្យសិក្សា ដល់មហាវិទ្យាល័យ តាមរយៈការទៅសិក្សានៅតាមសាលាឯកជននានា
- ការសិក្សាបំប៉នបន្ថែម ដូចជា៖ ភាសាខ្មែរ គណិតវិទ្យា ពីកម្រិតបឋមសិក្សា ដល់ថ្នាក់វិទ្យាល័យ ភាសាអង់គ្លេស កុំព្យូទ័រ សិល្បៈ របាំ ចុងភៅ កីឡា ការសិក្សា និងការអប់រំបំណិនជីវិតនៅក្នុងមណ្ឌល
- ការចូលរួម និងដឹកនាំល្បែងកំសាន្តផ្នែកអប់រំ កីឡា ដើម្បីអភិវឌ្ឍផ្នែកបញ្ញា
- ការលើកស្ទួយសិទ្ធិកុមារ ជាពិសេសសិទ្ធិក្នុងការបញ្ចេញមតិ

- ដំណើរកំសាន្ត និងទស្សនកិច្ចសិក្សាក្នុងស្រុក
- ការអប់រំសុខភាព មានគិលានុបដ្ឋាយិកាប្រចាំមណ្ឌល ប្រអប់សង្គ្រោះបឋម ការពិនិត្យសុខភាពមាត់ធ្មេញ បញ្ជូននិងផ្តល់ថ្លៃសេវាព្យាបាលជម្ងឺដល់កុមារនៅតាមមន្ទីរពេទ្យរដ្ឋ និងឯកជន និងសម្ភារអនាម័យ
- អនុញ្ញាតឱ្យកុមារបានទៅលេងស្រុកកំណើតក្នុងពិធីបុណ្យជាតិ ក្នុងករណីពិសេសផ្សេងៗ និងក្រុមគ្រួសារអាចជួបកុមារក្នុងមណ្ឌល។

ខ.ផ្តល់ការឧបត្ថម្ភគាំទ្រ ដល់ការថែទាំសុខភាពកុមារ និងយុវជន នៅតាមមន្ទីរពេទ្យរដ្ឋ និងឯកជន៖
- ថ្លៃសេវាព្យាបាលជម្ងឺធ្ងន់ និងស្រាល ដល់កុមារនៅមន្ទីរពេទ្យរដ្ឋ និងឯកជន
- ការអប់រំសុខភាព អនាម័យខ្លួនប្រាណ អនាម័យបរិស្ថាន តាមរយៈគិលានុប្បដ្ឋាកយិកាប្រចាំអង្គការ
- បណ្តុះបណ្តាលវគ្គជំនួយសង្គ្រោះបឋម និងពិនិត្យសុខភាពមាត់ធ្មេញតាមកាលកំណត់របស់គ្រូពេទ្យ
- មានគ្រូពេទ្យស្ម័គ្រចិត្តមកពីក្រៅប្រទេស និងពេទ្យអង្គការដៃគូពិនិត្យសុខភាពទូទៅជូនកុមារ។

គ.ផ្តល់ការឧបត្ថម្ភគាំទ្រ ដល់កុមារ យុវជនរងគ្រោះ និងងាយរងគ្រោះ នៅតាមសហគមន៍៖
- ការឧបត្ថម្ភដល់កុមារក្នុងសហគមន៍ និងគ្រួសារ នូវគ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ សម្ភារសិក្សា សេវាថែទាំសុខភាព ការសិក្សាភាសាអង់គ្លេស ការលេងកំសាន្ត និងកីឡា ដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អដែលមានលទ្ធភាព និងសមត្ថភាពរស់នៅខ្លួនឯងក្នុងសហគមន៍
- សេវាសិក្សាអប់រំបន្ថែមក្រៅម៉ោង ដូចជា៖ កសិកម្ម កុំព្យូទ័រ តូរ្យតន្ត្រី និងរបាំ ដល់កុមារនៅក្នុងទីតាំងមណ្ឌល
- អង្ករជូនគ្រួសារក្រីក្រតាមសហគមន៍ ផ្អែកលើស្ថានភាពជាក់ស្តែង និងតាមលទ្ធភាពរបស់អង្គការ
- ថ្លៃសេវាព្យាបាលជម្ងឺធ្ងន់ធ្ងរ ចំពោះគ្រួសារដែលគ្មានលទ្ធភាព។

ឃ.ការពង្រឹងសម្ថភាពបុគ្គលិក៖

បុគ្គលិកអង្គការទាំងអស់ត្រូវបានរៀនបំប៉នបន្ថែមនូវជំនាញផ្សេងៗ ដូចជា៖ ការថែទាំកុមារ ការសង្គ្រោះបឋម ការពិគ្រោះយោបល់ចិត្តសាស្ត្រតាមរយៈអ្នកជំនាញស្ម័គ្រចិត្ត។

ក្រុមគោលដៅដែលទទួលបានសេវាខាងលើ គឺជាលទ្ធផលនៃសហប្រតិបត្តិការ រវាងអង្គការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ចំនួនក្រុមគោលដៅទទួលបានផលប្រយោជន៍កម្មវិធី៖

| ល.រ | ក្រុមគោលដៅ | ចំនួន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ស្រី | ប្រុស | សរុប | |
| ១ | កុមារក្នុងមណ្ឌល | ១៣ | ១២ | ២៥ | |
| ២ | កុមារមកពីសហគមន៍ | ១០ | ១០ | ២០ | |
| ៣ | យុវជនក្រោយសមាហរណកម្ម | ១ | ០ | ១ | |
| | សរុប | ២៤ | ២២ | ៤៦ | |

# លក្ខខណ្ឌលម្អិត

# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# និង

# អង្គការ LITTLE HEARTS ORGANIZATION

# បានព្រមព្រៀងដូចខាងក្រោមនេះ

## មាត្រា ១

## លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះ គឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការ រវាង**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**អង្គការ** Little Hearts Organization ទាំងការអនុវត្ត និងវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធី ត្រូវបានពិភាក្សាជាមួយនឹងមន្ទីរជំនាញថ្នាក់រាជធានី ខេត្ត ដែលមានការពាក់ព័ន្ធ។

១.៣ រាល់ការសាងសង់សំណង់ណាមួយ ត្រូវធ្វើការពិភាក្សាល្អិតល្អន់ ជាមួយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាមុនសិនទើបអាចដំណើរការបាន។ រាល់គម្រោងនិងប្លង់សាងសង់រួមទាំងក្បាច់រចនា ត្រូវធ្វើឡើងស្របតាមបទដ្ឋានជាតិ។

១.៤ កាលបរិច្ឆេទនៃគម្រោងចាប់ផ្តើមនៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥
និងបញ្ចប់ទៅវិញថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៨ ។

១.៥ ក្នុងភាពជាដៃគូការងារ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**អង្គការ** Little Hearts Organization បានឯកភាពគ្នាថានឹងធ្វើការពិនិត្យឡើងវិញលើគម្រោងនេះ យ៉ាងតិច៣ខែ មុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយ សេចក្តីសម្រេចរួមគ្នានឹងត្រូវធ្វើឡើងថា តើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ ឬក៏ស្វែងរកកិច្ចបន្តគម្រោងនេះមួយរយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**អង្គការ** Little Hearts Organization សម្រាប់ជាមូលដ្ឋាន ក្នុងការធ្វើសហប្រតិបត្តិការ។

១.៧ **អង្គការ** Little Hearts Organization ត្រូវគោរពតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី**១២ ខែសីហា ឆ្នាំ២០១៥** ។

## មាត្រា ២

## អង្គការ Little Heart Organization បានព្រមព្រៀង៖

២.១ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងជាក់លាក់ដូចខាងក្រោម៖

- ផ្តល់ការថែទាំរយៈពេលវែងក្នុងបរិយាកាសជាលក្ខណៈគ្រួសារ ដល់កុមារកំព្រា និងកុមាររងគ្រោះ នៅក្នុងមណ្ឌលថែទាំកុមារ ដើម្បីឱ្យស្ថានភាពរស់នៅប្រចាំថ្ងៃរបស់កុមារកាន់តែប្រសើរឡើង
- ផ្តល់ការឧបត្ថម្ភដល់កុមារក្នុងសហគមន៍ និងគ្រួសារ នូវគ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ សម្ភារសិក្សា សេវាថែទាំសុខភាព និងការសិក្សាភាសាអង់គ្លេស ការលេងកំសាន្ត និងកីឡា ដើម្បីក្លាយខ្លួនទៅជាពលរដ្ឋល្អដែលមានលទ្ធភាព និងសមត្ថភាពរស់នៅខ្លួនឯងក្នុងសហគមន៍។

២.២ សហការយ៉ាងជិតស្និទ្ធជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដែលជាដៃគូការងារដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមាក្នុងការផ្ទេរ និងពង្រឹងជំនាញបច្ចេកទេស។

២.៣ រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណាដែលបានពីសមិទ្ធផលរបស់គម្រោងនេះ ត្រូវដាក់ជូនក្រសួងផ្តល់យោបល់រួចហើយ នឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នា របស់**អង្គការ** Little Hearts Organization និង**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

២.៤ ចូលរួមឱ្យបានទៀងទាត់រាល់កិច្ចប្រជុំនីមួយៗតាមការអញ្ជើញរបស់**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោង ដែលកំពុងដំណើរការ ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នា ដើម្បីឈានទៅសម្រេចជោគជ័យ តាមទិសដៅរបស់គម្រោង។

២.៥ ផ្តល់ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(នៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក) និងចម្លងជូន នាយកដ្ឋានសហប្រតិបត្តការ នាយកដ្ឋានកិច្ចការពារកុមារ និងមន្ទីរក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងការិយាល័យ សង្គមកិច្ច សុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ដែលអង្គការធ្វើសកម្មភាពនូវ៖

- របាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ដែលតម្រូវឱ្យផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឱ្យហួស ពីដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់ (មាត្រា ២៥ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល)
- របាយការណ៍អនុវត្តន៍កិច្ចព្រមព្រៀងគម្រោង ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ។

២.៦ ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីក្រសួង និងអង្គការបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរួចមក បើ **អង្គការ** Little Hearts Organization ពុំបានផ្ញើ របាយការណ៍ដូចមានចែងនៅក្នុងមាត្រា២.៥ ក្រសួងកំណត់ថា**អង្គការ** Little Hearts Organization ពុំបានអនុវត្តគម្រោងកម្មវិធីហើយត្រូវចាត់ទុកជាមោឃៈ និងអស់សុពលភាពដោយស្វ័យប្រវត្តិ។

២.៧ ទទួល ឬបង្កលក្ខណៈដល់មន្ត្រីរបស់ **ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការក្នុងគម្រោងកម្មវិធីដោយយោងលើប្រភេទគម្រោងកម្មវិធីដូចជា មធ្យោបាយធ្វើដំណើរ កិច្ចសម្របសម្រួល ទំនាក់ទំនងការងារ។

២.៨ ជូនដំណឹងមក **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាលាយលក្ខណ៍អក្សរ នៅពេលដែលអង្គការផ្លាស់ប្តូរអាសយដ្ឋាន ប្រធានអង្គការ គម្រោងកម្មវិធី លេខទូរស័ព្ទ និងទូរសារទំនាក់ទំនង។ ចំពោះករណីមានការនាំចូលឧបករណ៍ និងសម្ភារៈដែលយកមកប្រើប្រាស់សម្រាប់សកម្មភាពគម្រោង**អង្គការ** Little Hearts Organization ត្រូវជូនដំណឹងមក **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមពេលវេលាសមស្រប មុនពេលដែលឧបករណ៍ និងសម្ភារៈនោះគ្រោងនាំចូលមកដល់ទឹកដីព្រះរាជាណាចក្រកម្ពុជា។

២.៩ គម្រោងថវិកាដែលបានអនុម័តត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់។

២.១០ ជំនួយរបស់**អង្គការ** Little Hearts Organization ជាជំនួយ សម្រាប់មនុស្សធម៌សុទ្ធសាធ នឹងមិនប្រើប្រាស់ជំនួយនេះ ក្នុងគោលបំណងនយោបាយ សាសនា ឬយោធាឡើយ។

២.១១ គោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋាន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាអាទិ៍ៈ

- អនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អនុក្រឹត្យលេខ៣៤ .អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមារ របស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ
- អនុក្រឹត្យលេខ ១១៩ .អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ
- ប្រកាសលេខ០៣៩ ស.អ.យ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែកន្លែងថែទាំ និងការបិទ កន្លែងថែទាំកុមារ
- ប្រកាសលេខ១១៩ ស.អ.យ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌
- ប្រកាសលេខ ២២៨០ ស.អ.យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- ប្រកាសលេខ ១៨០១ ស.អ.យ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ
- ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍
- ប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល
- ប្រកាសលេខ ២៣៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ

- ប្រកាសលេខ ១០០ ស.អ.យ. ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ថែទាំជំនួសចំពោះកុមារ។

២.១២ អង្គការត្រូវសហការជាមួយក្រសួងស.អ.យ. លើកម្មវិធីបង្រួបបង្រួមគ្រួសារ ដើម្បីបំពេញកិច្ចការឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយការទទួលខុសត្រូវ។ អង្គការត្រូវធ្វើការវាយតម្លៃ ១ឆ្នាំម្តងពីលទ្ធភាពធ្វើសមាហរណកម្មឱ្យកុមារទៅរស់នៅជាមួយគ្រួសារ សាច់ញាតិ ឪពុកម្តាយធម៌ នៅក្នុងសហគមន៍។ ក្នុងរយៈពេល២ឆ្នាំដំបូង បុគ្គលិកអង្គការត្រូវចុះតាមដានកុមារ ដែលបានធ្វើសមាហរណកម្មជារៀងរាល់ត្រីមាស។ ចាប់ពីឆ្នាំ២០១៨ ការទទួលទុកដាក់កុមារត្រូវបំពេញទម្រង់គ្រប់គ្រងករណីថ្មី និងគំរូលិខិតបទដ្ឋានឱ្យស្របតាមការអនុវត្តប្រកាសស្តីពី នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ។

២.១៣ អនុញ្ញាតឱ្យមន្ត្រី **ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ចុះត្រួតពិនិត្យវាយតម្លៃ និងតាមដានគម្រោងកម្មវិធីរបស់អង្គការ។

២.១៤ សហការជាមួយក្រសួងស.អ.យ. ដើម្បីទទួលការបណ្តុះបណ្តាល ស្តីពីអង្គការសុវត្ថិភាពកុមារ (Child Safe Organisation )ដល់បុគ្គលិកអង្គការ និងអ្នកគ្រប់គ្រង អ្នកថែទាំនៅក្នុងមណ្ឌលថែទាំ។

២.១៥ ផ្តល់ច្បាប់ថតចម្លងកិច្ចព្រមព្រៀងនេះទៅនាយកដ្ឋានជំនាញ និង**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ដែលអង្គការធ្វើសកម្មភាពក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមព្រៀង៖

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ក្រសួង មន្ទីរ ក្រុង ស្រុក ខណ្ឌ)ឱ្យបំពេញការងារ ជាមួយ**អង្គការ** Little Hearts Organization ដើម្បីឱ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធិភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឱ្យ**អង្គការ** Little Hearts Organization អាចជួលបុគ្គលិក កម្ពុជាធ្វើការបានដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឱ្យបុគ្គលិក និងទីប្រឹក្សារបស់អង្គការដែលចូលរួមក្នុងសកម្មភាពគម្រោង ដែលត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ សម្របសម្រួលតាមករណីសមស្របដើម្បីស្នើសុំពន្ធ និងអាករជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជាដល់ឧបករណ៍ និងសម្ភារៈដែលយកមកប្រើប្រាស់គាំទ្រឱ្យសកម្មភាពគម្រោង។

៣.៥ ជំរុញឱ្យមន្ទីរជំនាញរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ធ្វើការប្រាស្រ័យទាក់ទងឱ្យបានជិតស្និទ្ធជាមួយអង្គការ ដើម្បីជួយកសាងផែនការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៦ រាល់សំណើផ្សេងៗពីអង្គការ នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ។

៣.៧ អនុញ្ញាតឱ្យ**អង្គការ** Little Hearts Organization ពិភាក្សាជាមួយ នាយកដ្ឋានជំនាញ ឬអង្គភាពពាក់ព័ន្ធរបស់**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** លើកិច្ចដំណើរការដើម្បីសម្រេចបាននូវការព្រមព្រៀងផ្សេងៗ ស្របតាមលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងរួចស្នើសុំសេចក្តីសម្រេចពីរដ្ឋមន្ត្រី **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**។

## មាត្រា ៤
## លក្ខខណ្ឌរួម

៤.១ ប្រធាន**អង្គការ** Little Hearts Organization ត្រូវជ្រើសតាំងជាតំណាងស្របច្បាប់ ដោយ **អង្គការ** Little Hearts Organization នឹងត្រូវផ្តល់សិទ្ធិជាតំណាងអង្គការនេះដើម្បីធ្វើការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់តាមការសម្រេចរួមគ្នាមួយរវាងតំណាង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**អង្គការ** Little Hearts Organization ក្រោយពីបានពិគ្រោះ និងពិចារណារួចរាល់ហើយ។

៤.៤ **អង្គការ** Little Hearts Organization មានសិទ្ធិបញ្ឈប់សកម្មភាព ភ្លាមលើកិច្ចព្រមព្រៀងនេះ ក្រោយពីបានពិភាក្សាជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ប្រសិនជាពិនិត្យឃើញថា គ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ ការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងប្រធានស័ក្ត។

៤.៥ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយចេញលិខិតរបស់ក្រសួងជាផ្លូវការ ប្រសិនបើការអនុវត្តដំណោះស្រាយ ដូចក្នុងមាត្រា ៤.២ ៤.៣ និង៤.៤ នៃកិច្ចព្រមព្រៀងនេះមិនអាចសម្រេចបាន ឬមានគោលការណ៍ថ្មីតម្រូវ ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយ**អង្គការ** Little Hearts Organization រួច **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** នឹងស្នើសុំឱ្យអង្គការបញ្ឈប់ការងារចំពោះបុគ្គលិកណាដែលត្រូវបានវិនិច្ឆ័យថា ធ្វើឱ្យខូចកិត្តិយសក្រសួង ឬបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនហើយ **អង្គការ** Little Hearts Organization ត្រូវតែអនុវត្តតាមដំណើរការនេះ។

៤.៧ ក្រោយពីបានពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះ ប្រសិនបើតំណាងផ្លូវការរបស់**អង្គការ** Little Hearts Organization ត្រូវបានគេវិនិច្ឆ័យឃើញថាមិនបានបំពេញតាមមាត្រា២ នៃកិច្ចព្រមព្រៀងនេះ។

៤.៨ កិច្ចព្រមព្រៀងនេះ អនុញ្ញាតឱ្យអង្គការបន្តកិច្ចសហប្រតិបត្តិការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្នុងថេរវេលាដូចមានចែងក្នុងចំនុច១.៤ ។ ចំពោះការគ្រប់គ្រងកុមារ អង្គការត្រូវអនុវត្តតាមបទដ្ឋាននានាពាក់ព័ន្ធទៅនឹងកុមារដែលក្រសួងស.អ.យ. បានផ្សព្វផ្សាយអនុវត្ត ហើយការទទួលខុសត្រូវ ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកវិស័យកុមាររបស់ក្រសួងស.អ.យ. បន្តធ្វើសមាហរណកម្មកុមារក្នុងទិសដៅបង្រួបបង្រួមកុមារក្នុងគ្រួសារ ដូចនេះតម្រូវឱ្យអង្គការត្រូវបំពេញបែបបទ និងលក្ខខណ្ឌនានាដែលមានការបញ្ជាក់ពីការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ។

៤.៩ ប្រសិនបើ**អង្គការ** Little Hearts Organization មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា** អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការនោះរួចមក។

៤.១០ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាហើយមានសុពលភាពរហូតដល់ថ្ងៃបញ្ចប់គម្រោង។

*កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើងដោយឥតកែប្រែជាភាសាខ្មែរចំនួនពីរច្បាប់។*

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៤...................

**ហត្ថលេខី**

**តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**បណ្ឌិត ស៊ូនី ខេមរិសិដ្ឋ**
**រដ្ឋលេខាធិការ**

**តំណាងអង្គការ** LITTLE HEARTS ORGANIZATION

TONY GEERAERTS
**នាយកអង្គការ**

## ឧបសម្ព័ន្ធ គម្រោងថវិកាចំណាយរបស់អង្គការ Little Hearts Organization

| គម្រោងចំណាយ | ឆ្នាំ២០២៥ | ឆ្នាំ២០២៦ | ឆ្នាំ២០២៧ | សរុបទឹកប្រាក់ (គិតជាដុល្លា) |
|---|---|---|---|---|
| ចំណាយលើប្រាក់ខែបុគ្គលិក | 30,000 | 30,000 | 30,000 | 90,000 |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាលផ្សេងៗ(ថ្លៃទឹក ភ្លើង ទូរស័ព្ទនិងអ៊ីនធឺណេត) | 3,000 | 3,000 | 3,000 | 9,000 |
| **សរុបចំណាយមិនផ្ទាល់** | **33,000** | **33,000** | **33,000** | **99,000** |
| ចំណាយលើការបណ្តុះបណ្តាល | 37,400 | 37,300 | 38,000 | 112,700 |
| ចំណាយលើសិក្ខាសាលាពង្រឹងសមត្ថភាពបុគ្គលិក | 1,600 | 1,600 | 1,600 | 4,800 |
| ការផ្គត់ផ្គង់សម្ភារៈបច្ចេកទេសសម្រាប់សិក្សា | 2,000 | 2,000 | 2,000 | 6,000 |
| ចំណាយលើការធ្វើដំណើរ និងដឹកជញ្ជូន ជួសជុល ថែទាំ | 9,000 | 9,000 | 9,000 | 27,000 |
| ចំណាយលើការសង្គ្រោះបឋម និងការព្យាបាលជំងឺដល់កុមារ | 3,000 | 3,000 | 3,000 | 9,000 |
| ចំណាយលើការសិក្សាបន្ថែមគ្រប់កំរិតនិងថ្នាក់បំប៉នត្រៀមប្រលង | 20,000 | 20,000 | 20,000 | 60,000 |
| ចំណាយលើអាហារ ៣ពេលក្នុង១ថ្ងៃ | 40,000 | 40,000 | 40,000 | 120,000 |
| ចំណាយលើថ្នាំពេទ្យ ការសិក្សា សម្ភារៈ និងសំលៀកបំពាក់ | 3,500 | 3,500 | 3,500 | 10,500 |
| ចំណាយលើការថ្លៃសិក្សាជំនាញ និងមហាវិទ្យាល័យ | 25,000 | 25,000 | 25,000 | 75,000 |
| ចំណាយលើជំនួយសហគមន៍ | 3,000 | 3,000 | 3,000 | 9,000 |
| ចំណាយលើប្រាក់ឧបត្ថម្ភប្រកបមុខរបរ | 2,000 | 2,000 | 2,000 | 6,000 |
| **សរុបចំណាយផ្ទាល់** | **146,500** | **146,400** | **147,100** | **440,000** |
| **ថវិការសរុបរបស់គម្រោង** | **179,500** | **179,400** | **180,100** | **539,000** |